## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ១២៣,៣៤០ ដុល្លារអាមេរិកសម្រាប់ការសាងសង់អគារបណ្តុះបណ្តាល



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ១២៣,៣៤០ ដុល្លាអាមេរិក ដល់មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម សម្រាប់គម្រោងសាងសង់អគារបណ្តុះបណ្តាល ក្នុងមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានាថ្ងៃនេះដោយឯកឧត្តម ម៉ាសាហ៊ិរូមី គូរ៉ូគី ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណា ចក្រកម្ពុជា និងលោកវេជ្ជបណ្ឌិត មាស ជា ប្រធានមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាមនៅស្ថានទូតជប៉ុន។

ដើម្បីបង្កើនសេវាបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល ក៏ដូចជាសិស្ស-និសិត្សផ្នែកសុខាភិបាលឲ្យកាន់តែប្រសើរឡើង មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាមនឹងអនុវត្តគម្រោងសាងសង់អគារបណ្តុះបណ្តាលដែលរួមមានបន្ទប់សិក្សា និងបន្ទប់ស្នាក់នៅ។ អ្នកឯកទេស និងសិស្ស-និសិត្សផ្នែកសុខាភិបាលប្រមាណ១,០០០នាក់នឹងទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ។ ជាងនេះទៅទៀត ប្រជាជនប្រមាណ ១,៧០០,០០០ នាក់ដែលរស់នៅក្នុងខេត្ត នឹងទទួលបានអត្ថប្រយោជន៍ពីការកែលម្អសេវាសុខាភិបាលក្នុងមន្ទីរពេទ្យ ដោយបុគ្គលិកមន្ទីរពេទ្យមិនចាំបាច់ចំណាយពេលវេលាធ្វើដំណើរទៅទទួលការបណ្តុះបណ្តាលនៅឆ្ងាយពីមន្ទីរពេទ្យ ហើយជាមួយគ្នានេះ ពួកគេអាចទទួលបានការបណ្តុះបណ្តាលដែលមិនប៉ះពាល់ដល់ការផ្តល់សេវានៅមន្ទីរពេទ្យ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ*(ជំនួយគូសាណូណិ)* របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅ

ការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជុំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៤៧.៧លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និង អង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៧៥គម្រោងនៅទូទាំងប្រទេស។



---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*